# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីសមភាពតាមផ្លូវលោកនិងតាមផ្លូវធម៌

Website: www.hoksavann.org
ថ្ងៃទី២១ វិច្ឆិកា ២០០៤

### ១- អំពីសមភាពតាមផ្លូវលោក

ពាក្យថាសមភាពប្រែថាភាពស្មើគ្នា ដំណើរស្មើមុខគ្នា ប៉ុនគ្នាឬដូចគ្នាចំពោះមុខច្បាប់ ។ ដូចជាពលរដ្ឋម្នាក់មានសិទ្ធិរៀនសូត្រ សិទ្ធិនិយាយបញ្ចេញមតិ សិទ្ធិរកស៊ី សិទ្ធិបង្កើតសមាគម សិទ្ធិធ្វើរដ្ឋការ សិទ្ធិខាងជំនឿ សិទ្ធិសរសេរសារពត៌មាន សរសេរសៀវភៅទស្សនាវដ្ដី សិទ្ធិធ្វើបាតុកម្ម កូដកម្ម, ពលរដ្ឋដទៃទៀតក៏មានសិទ្ធិនេះដូចគ្នា ទោះបីខុសគ្នាដោយសម្បត្តិ ដោយឋានៈ ដោយជាតិត្រកូលក៏ដោយ ។ នេះជាសមភាពប្រកបដោយយុត្តិធម៌ដែលប្រទេសកាន់របបប្រជាធិបតេយ្យនិងច្បាប់អ.ស.ប. បានចែងនិងអនុវត្តមកហើយ ។ បើនិយាយអំពីទោសកំហុសដែលត្រូវឡើងតុលាការ បើប្រជាពលរដ្ឋធ្វើខុសឡើងតុលាការ អ្នករដ្ឋការគ្រប់តំណែងដែលធ្វើខុសក៏ត្រូវឡើងតុលាការកាត់ទោសដូចគ្នា ។

### ២- អំពីសមភាពតាមផ្លូវធម៌

សមភាពតាមន័យផ្លូវធម៌របស់ព្រះពុទ្ធសាសនា គឺស្មើគ្នាចំពោះមុខអំពើរបស់ខ្លួន ។ សេចក្ដីថា អ្នកមានក្ដីអ្នកក្រក្ដី អ្នកធំក្ដីអ្នកតូចក្ដី បើមានចិត្តសៅហ្មងប្រព្រឹត្តិអំពើអាក្រក់ ត្រូវតែទទួលផលអាក្រក់តាមអំពើរបស់ខ្លួន បើមានចិត្តបរិសុទ្ធប្រព្រឹត្តល្អ ក៏ត្រូវទទួលផលល្អតាមអំពើរបស់ខ្លួនដែរ ។ នេះជាសមភាពចំពោះមុខអំពើរបស់ខ្លួន ដែលជាច្បាប់ធម្មជាតិសកល ប្រកបដោយយុត្តិធម៌របស់ព្រះពុទ្ធសាសនា ។ កំពស់និងទំនាបរបស់មនុស្សស្ថិតនៅលើអំពើរបស់ខ្លួន បានសេចក្ដីថា មនុស្សមានតម្លៃខ្ពង់ខ្ពស់និងថោកទាប ត្រូវកើតចេញមកអំពីអំពើល្អអាក្រក់របស់ខ្លួន។ បើគេប្រព្រឹត្តល្អដោយកាយវាចាចិត្ត គេជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ, បើគេប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គេជាមនុស្សថោកទាប គឺយកអំពើល្អនិងអំពើអាក្រក់ជាខ្នាតសំរាប់វាស់ ពុំមែនយកទ្រព្យសម្បត្តិបុណ្យសក្តិជាតិត្រកូលជាខ្នាតសំរាប់វាស់ឡើយ ។ បើមនុស្សមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានបុណ្យសក្តិធំដុំ មានជាតិត្រកូលខ្ពង់ខ្ពស់ តែប្រព្រឹត្តអំពើអាក្រក់ដោយកាយវាចាចិត្ត ចាត់ទុកជាមនុស្សថោកទាប ។ ផ្ទុយទៅវិញបើមនុស្សក្រីក្រលំបាកតោកយ៉ាកឥតបុណ្យឥតសក្តិ មានជាតិត្រកូលទាប តែជាមនុស្សប្រព្រឹត្តល្អដោយកាយវាចាចិត្ត មិនបៀតបៀនអ្នកដទៃ ត្រូវចាត់ទុកជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ ។ ចំពោះសមភាពខាងការគោរពព្រះពុទ្ធសាសនា គឺមនុស្សគ្រប់ជាន់ថ្នាក់អាចមានសិទ្ធិចូលកាន់ព្រះពុទ្ធសាសនាបានដូចគ្នា មាននាមជាទាយកទាយិកា ជាឧបាសកឧបាសិកា ជាភិក្ខុសាមណេរតាមកម្រឹតធម៌វិន័យ ដែលខ្លួនអាចទទួលកាន់យកបានតាមសទ្ធាជ្រះថ្លា ។ មួយទៀត បុគ្គលគ្រប់រូបមានសិទ្ធិត្រាស់ជាព្រះពុទ្ធបានដូចគ្នាឲ្យតែកសាងបារមីទាំង១០បានពេញបរិបូណ៌ ។

សមភាពនេះ ផ្លូវលោកនិងផ្លូវធម៌សឹងតែដូចគ្នា ត្រង់ន័យព្រះពុទ្ធសាសនាថា អ្នកសាងអំពើអាក្រក់ត្រូវទទួលផលអាក្រក់ ទោះអ្នកមានក្តីអ្នកក្រក្តី អ្នកធំក្តីអ្នកតូចក្តី ផ្សេងគ្នាដោយជាតិត្រកូលក្តី ។ ឯផ្លូវលោកក៏ចែងថា ជនណាប្រព្រឹត្តរំលោភច្បាប់ឬរំលោភសិទ្ធិមនុស្ស ត្រូវមានទោស ទោះអ្នកមានក្តី អ្នកក្រក្តី អ្នកធំក្តី អ្នកតូចក្តី អ្នកមានជាតិត្រកូលផ្សេងគ្នាក្តី ។ បានសេចក្តីថា បើប្រជាពលរដ្ឋធ្វើខុសច្បាប់រដ្ឋ ត្រូវឡើងតុលាការកាត់សេចក្តី អ្នករដ្ឋការគ្រប់តំណែងរហូតដល់រដ្ឋមន្ត្រី បើធ្វើខុសច្បាប់រដ្ឋក៏ត្រូវឡើងតុលាការកាត់សេចក្តីវិនិច្ឆ័យទោសដូចគ្នានឹងប្រជាពលរដ្ឋដែរ ។ នេះជាភាពស្មើគ្នាចំពោះមុខច្បាប់ ពុំមែនស្មើគ្នាដោយទ្រព្យសម្បត្តិដូចលទ្ធិកុម្មុយនិស្តចែងទេ ព្រោះនិស្ស័យវាសនាការព្យាយាមរបស់មនុស្សមានលក្ខណៈផ្សេងៗគ្នា ។ ប៉ុន្តែព្រះពុទ្ធសាសនាចែងអំពីការទទួលផលនៃអំពើច្បាស់លាស់និងជ្រៅជាងច្បាប់ផ្លូវលោក គឺច្បាប់ផ្លូវធម៌ត្រូវតែទទួលផលនៃអំពើរបស់ខ្លួននៅពេលណាមួយ ទោះបីអំពើដែលធ្វើនោះគ្មានគេដឹងឮក៏ដោយ ចំណែកច្បាប់ផ្លូវលោក បុគ្គលត្រូវទទួលផលនៃអំពើលុះត្រាតែមានភស្តុតាងនិងសាក្សីដឹងឮថា បុគ្គលនោះបានប្រព្រឹត្តធ្វើអំពើនេះពិតមែន ។៚